ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ : ៥១ អនក្រ.បក

# អនុក្រឹត្យ

## ស្តីពី

## ការបង្កើតក្រុមប្រឹក្សាកីឡាក្រសួងមហាផ្ទៃ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៣២០/៤២១ ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២០ ស្តីពីការតែងតាំង និងកែសម្រួលសមាសភាពរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី៣០ ខែតុលា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៥០១/១៧៨ ចុះថ្ងៃទី២២ ខែឧសភា ឆ្នាំ២០០១ ស្តីពីលក្ខន្តិកៈដោយឡែក នៃក្របខ័ណ្ឌមន្ត្រីនគរបាលជាតិកម្ពុជា
- បានឃើញអនុក្រឹត្យលេខ១០៩ អនក្រ.បក ចុះថ្ងៃទី១៩ ខែសីហា ឆ្នាំ២០១៥ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងមហាផ្ទៃ
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

## សម្រេច

## ជំពូកទី១

## បទប្បញ្ញត្តិទូទៅ

**មាត្រា១._**

ត្រូវបានបង្កើតក្រុមប្រឹក្សាកីឡាក្រសួងមហាផ្ទៃ ហៅកាត់ថា "**ក.ក.ម.ផ**" ដែលមានគោលបំណងលើកកម្ពស់វិស័យកីឡារបស់កងកម្លាំងនគរបាលជាតិ និងរួមគ្នាអភិវឌ្ឍសមត្ថភាព បច្ចេកទេសឱ្យមានការរីកចម្រើនដើម្បីធ្វើសមាហរណកម្មចូលជាសមាជិក សហភាពកីឡានគរបាលជាតិអន្តរជាតិ International Police Sport Union សរសេរជាអក្សរកាត់ " IPSU " ។

**មាត្រា២._**

អនុក្រឹត្យនេះ មានគោលដៅកំណត់អំពី៖

- សមាសភាពរបស់ក្រុមប្រឹក្សាកីឡាក្រសួងមហាផ្ទៃ
- តួនាទី និងភារកិច្ចរបស់ក្រុមប្រឹក្សាកីឡាក្រសួងមហាផ្ទៃ
- រចនាសម្ព័ន្ធរបស់អគ្គលេខាធិការដ្ឋាននៃក្រុមប្រឹក្សាកីឡាក្រសួងមហាផ្ទៃ។

**មាត្រា៣._**

អនុក្រឹត្យនេះមានវិសាលភាពចំពោះវិស័យកីឡារបស់កងកម្លាំងនគរបាលជាតិ ទាំងនៅថ្នាក់ជាតិ និងអន្តរជាតិ។

## ជំពូកទី២
## សមាសភាព តួនាទី និងភារកិច្ចរបស់ក្រុមប្រឹក្សាកីឡាក្រសួងមហាផ្ទៃ

**មាត្រា៤._**

ក្រុមប្រឹក្សាកីឡាក្រសួងមហាផ្ទៃ មានសមាសភាពដូចខាងក្រោម៖

| | |
|---|---|
| ១-សម្តេចក្រឡាហោម **ស ខេង** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃប្រធាន | |
| ២-អគ្គស្នងការ នៃអគ្គស្នងការដ្ឋាននគរបាលជាតិ | អនុប្រធានទី១ |
| ៣-រដ្ឋលេខាធិការក្រសួងមហាផ្ទៃ ទទួលបន្ទុកពត៌មាន និងកីឡា | អនុប្រធានទី២ |
| ៤-រដ្ឋលេខាធិការ និងជានាយខុទ្ទកាល័យ រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ | អនុប្រធានអចិន្ត្រៃយ៍ |
| ៥-រដ្ឋលេខាធិការក្រសួងមហាផ្ទៃ ចំនួន ០៥រូប | អនុប្រធាន |
| ៦-អគ្គនាយក នៃអគ្គនាយកដ្ឋានរដ្ឋបាល | អនុប្រធាន |
| ៧-អគ្គនាយក នៃអគ្គនាយកដ្ឋានភស្តុភារ និងហិរញ្ញវត្ថុ | អនុប្រធាន |
| ៨-អគ្គនាយក នៃអគ្គនាយកដ្ឋានអត្តសញ្ញាណកម្ម | អនុប្រធាន |
| ៩-អគ្គនាយក នៃអគ្គនាយកដ្ឋានអន្តោប្រវេសន៍ | អនុប្រធាន |
| ១០-អគ្គលេខាធិការ នៃអគ្គលេខាធិការដ្ឋាន ក្រសួងមហាផ្ទៃ | អនុប្រធាន |
| ១១- អគ្គនាយក នៃអគ្គនាយកដ្ឋានសវនកម្មផ្ទៃក្នុង | អនុប្រធាន |
| ១២- អគ្គនាយក នៃអគ្គនាយកដ្ឋានពន្ធនាគារ | អនុប្រធាន |
| ១៣- អគ្គាធិការ នៃអគ្គាធិការដ្ឋាន | អនុប្រធាន |
| ១៤- ប្រធានក្រុមប្រឹក្សានីតិកម្ម | អនុប្រធាន |
| ១៥- ប្រធានបណ្ឌិត្យសភានគរបាលជាតិកម្ពុជា | អនុប្រធាន |
| ១៦- ប្រធានអង្គភាពកីឡានគរបាលជាតិកម្ពុជា | អគ្គលេខាធិការ |
| ១៧- នាយនគរបាលជាតិជាន់ខ្ពស់ មួយចំនួន | អគ្គលេខាធិការរង |
| ១៨- អភិបាល នៃគណៈអភិបាលរាជធានី-ខេត្ត | សមាជិក |
| ១៩- ប្រធាននាយកដ្ឋាន និងអង្គភាពចំណុះក្រសួងមហាផ្ទៃ | សមាជិក |
| ២០- ស្នងការ នៃស្នងការដ្ឋាននគរបាលរាជធានី-ខេត្ត | សមាជិក។ |



**មាត្រា៥._**

ក្រុមប្រឹក្សាកីឡាក្រសួងមហាផ្ទៃ មានតួនាទី និងភារកិច្ចដូចខាងក្រោម៖

- គ្រប់គ្រង ដឹកនាំអង្គភាពកីឡានគរបាលជាតិ និងអង្គភាពជំនាញដទៃទៀតស្របតាមលក្ខន្តិកៈ របស់ក្រុមប្រឹក្សាកីឡាក្រសួងមហាផ្ទៃសម្រាប់អាណត្តិទី២ (ឆ្នាំ២០២០-២០២៤) និងអាណត្តិ បន្តបន្ទាប់ទៀត
- ដាក់ចេញនូវគោលដៅជាយុទ្ធសាស្ត្ររយៈពេលវែង ដើម្បីឱ្យអង្គភាព កីឡានគរបាលជាតិ អនុវត្ត តាមគោលការណ៍កែទម្រង់ស៊ីជម្រៅរបស់រាជរដ្ឋាភិបាល
- បែងចែកភារកិច្ចដឹកនាំ និងទទួលខុសត្រូវតាមវិស័យជំនាញកីឡានីមួយៗ ដោយអនុលោមតាមស្មារតីនៃអង្គប្រជុំវិសាមញ្ញ ដើម្បីអនុវត្តតាមសេចក្តីសម្រេចរបស់ប្រធានក្រុមប្រឹក្សាកីឡាក្រសួងមហាផ្ទៃ និងរួមចំណែកឱ្យបានខ្លាំងក្នុងការពង្រឹង កិច្ចអភិវឌ្ឍជនជានកីឡា ក្នុងកងកម្លាំងនគរបាលជាតិសំដៅលើកស្ទួយកិត្តិយសកិត្យានុភាពក្នុងវិស័យកីឡា ទាំងនៅថ្នាក់ជាតិ និងលើឆាកអន្តរជាតិ
- សហការជាមួយវិស័យកីឡាផ្សេងៗនៅតាមក្រសួង ស្ថាប័ននៃព្រះរាជាណាចក្រកម្ពុជា
- ពិនិត្យសមត្ថភាពជំនាញ កាយសម្បទារបស់កីឡាករ-កីឡាការិនី និងលើកសំណើសុំ **នាយករដ្ឋមន្ត្រី** បញ្ចូលក្នុងក្របខ័ណ្ឌកងកម្លាំងនគរបាលជាតិជំនួសឲ្យមន្ត្រី គ្រូបង្វឹក កីឡាករ-កីឡាការិនីចាស់ៗ ដែលត្រូវដាក់ឱ្យចូលនិវត្តន៍ជារៀងរាល់ឆ្នាំ មិនឱ្យលើសពី៣០% (សាមសិបភាគរយ)នៃកងកម្លាំងសរុបក្នុងអង្គភាពកីឡានគរបាលជាតិ ដោយគិតចាប់ពីឆ្នាំ២០២០ តទៅ។

## ជំពូកទី៣
## អគ្គលេខាធិការដ្ឋាន នៃក្រុមប្រឹក្សាកីឡាក្រសួងមហាផ្ទៃ

**មាត្រា៦._**

ក្រុមប្រឹក្សាកីឡា មានអគ្គលេខាធិការដ្ឋានមួយជាសេនាធិការ។

អគ្គលេខាធិការដ្ឋាន នៃក្រុមប្រឹក្សាកីឡាក្រសួងមហាផ្ទៃ ដឹកនាំដោយអគ្គលេខាធិការមួយរូប មានឋានៈ និងបុព្វសិទ្ធិស្មើអគ្គនាយក និងមានអគ្គលេខាធិការរងមួយចំនួនជាជំនួយការ មានឋានៈស្មើអគ្គនាយករង។

ប្រធានអង្គភាពកីឡានគរបាលជាតិកម្ពុជា ត្រូវតែងតាំងជាអគ្គលេខាធិការដោយព្រះរាជក្រឹត្យតាមនីតិវិធីជាធរមាន។

អគ្គលេខាធិការរង នៃក្រុមប្រឹក្សាកីឡាក្រសួងមហាផ្ទៃ ត្រូវតែងតាំងដោយអនុក្រឹត្យតាមនីតិវិធីជាធរមាន ។

អគ្គលេខាធិការដ្ឋាន នៃក្រុមប្រឹក្សាកីឡាក្រសួងមហាផ្ទៃ មានភារកិច្ចក្នុងការគ្រប់គ្រង ដឹកនាំ ជំរុញការអភិវឌ្ឍវិស័យកីឡា និងលើកទិសដៅផែនការយុទ្ធសាស្ត្រធានាបាននូវស្ថិរភាព និងការរីកចម្រើនខាងវិស័យកីឡាក្នុងកងកម្លាំងនគរបាលជាតិទូទាំងប្រទេស។

## ជំពូកទី៤
## រចនាសម្ព័ន្ធនៃអគ្គលេខាធិការដ្ឋាន នៃក្រុមប្រឹក្សាកីឡាក្រសួងមហាផ្ទៃ

**មាត្រា៧._**

អគ្គលេខាធិការដ្ឋានកីឡាក្រសួងមហាផ្ទៃមានអង្គភាពចំណុះចំនួន ០៥(ប្រាំ) ដូចខាងក្រោម៖

១-អង្គភាពរដ្ឋបាល-ហិរញ្ញវត្ថុ

២-អង្គភាពកីឡានគរបាលជាតិកម្ពុជា

៣-អង្គភាពបច្ចេកទេសកីឡាជំនាញ
៤-អង្គភាពសហប្រតិបត្តិការកីឡាអន្តរជាតិ
៥-អង្គភាពសវនកម្មផ្ទៃក្នុង។

**មាត្រា៨.-**

អង្គភាពរដ្ឋបាល-ហិរញ្ញវត្ថុ មានភារកិច្ចដូចខាងក្រោម៖
- សម្របសម្រួលសកម្មភាពការងាររបស់អគ្គលេខាធិការដ្ឋានកីឡា និងអង្គភាពនានាក្រោមឱវាទ
- ធានាប្រសិទ្ធភាពនូវដំណើរការការងាររដ្ឋបាល និងរៀបចំផែនការហិរញ្ញវត្ថុ របស់អគ្គលេខាធិការដ្ឋាន
- បញ្ជូន និងរក្សាទុកលិខិតស្នាម ឯកសារនានាតាមបញ្ជារបស់អគ្គលេខាធិការដ្ឋានកីឡា ឱ្យទាន់ពេលវេលា ធានាឱ្យបានគង់វង្ស និងរក្សាការសម្ងាត់
- ធ្វើការងារបុគ្គលិក ភស្តុភារ គណនេយ្យ និងបញ្ជីសារពើភណ្ឌទ្រព្យសម្បត្តិរដ្ឋ របស់អគ្គលេខាធិការដ្ឋាន
- គ្រប់គ្រង និងផ្គត់ផ្គង់មធ្យោបាយសម្ភារៈរដ្ឋបាល សម្រាប់ឲ្យអគ្គលេខាធិការដ្ឋានកីឡាដំណើរការ ប្រកបដោយនិរន្តរភាព និងប្រសិទ្ធភាព
- លើកគម្រោងថវិកាប្រចាំឆ្នាំរបស់អគ្គលេខាធិការដ្ឋាន
- លើកគម្រោងប្រេងឥន្ធនៈប្រចាំខែ ត្រីមាស និងប្រចាំឆ្នាំរបស់ថ្នាក់ដឹកនាំអគ្គលេខាធិការដ្ឋាន និងអង្គភាពចំណុះ
- រៀបចំបែបបទ និងសំណើផ្តល់មេដាយការងារ និងគ្រឿងឥស្សរិយយសផ្សេងៗជូនថ្នាក់ដឹកនាំ និងមន្ត្រីក្រោមឱវាទ
- ធ្វើរបាយការណ៍បូកសរុបការងារ និងទិសដៅបន្តរបស់អង្គភាពរដ្ឋបាល-ហិរញ្ញវត្ថុ តាមការ កំណត់
- បំពេញភារកិច្ចផ្សេងៗទៀតដែលអគ្គលេខាធិការប្រគល់ឱ្យ។

អង្គភាពរដ្ឋបាល-ហិរញ្ញវត្ថុ មានឋានៈស្មើនាយកដ្ឋាន ដឹកនាំដោយប្រធានមួយរូប និងមានអនុប្រធានមួយចំនួនតាមការកំណត់។

**មាត្រា៩.-**

អង្គភាពកីឡានគរបាលជាតិកម្ពុជា មានភារកិច្ចដូចខាងក្រោម៖
- កសាងផែនការ យុទ្ធសាស្ត្រ ពង្រឹងការគ្រប់គ្រង ដឹកនាំដើម្បីអភិវឌ្ឍលើគ្រប់វិស័យកីឡាក្រោមឱវាទក្រសួងមហាផ្ទៃឱ្យមានការរីកចម្រើនឆាប់រហ័ស
- ផ្សព្វផ្សាយ អប់រំដល់មន្ត្រីរាជការស៊ីវិល កងកម្លាំងនគរបាលជាតិឱ្យយល់ជ្រួតជ្រាបពីអត្ថប្រយោជន៍ នៃការហ្វឹកហាត់កីឡាដើម្បីសុខភាព និងសាមគ្គីភាព
- ទំនាក់ទំនងសហការជាមួយអង្គភាពក្រៅរដ្ឋាភិបាល អង្គការជាតិ-អន្តរជាតិ ក្រុមហ៊ុន និងសប្បុរសជនក្នុងការស្វែងរកជំនួយនានាសម្រាប់ទ្រទ្រង់កីឡា ដើម្បីកសាងឱ្យបាននូវហេដ្ឋារចនាសម្ព័ន្ធនានា សំដៅបម្រើឱ្យការហ្វឹកហាត់យូរអង្វែង
- លើកគម្រោងសាងសង់ ជួសជុល ពង្រីកទីតាំងដែលមានស្រាប់ ឬទីតាំងថ្មី សម្រាប់ហ្វឹកហាត់លើគ្រប់វិញ្ញាសាឱ្យមានលក្ខណៈសម្បត្តិអាចធ្វើជាម្ចាស់ផ្ទះក្នុងការរៀបចំប្រកួតជាលក្ខណៈអន្តរជាតិបាន
- កសាងផែនការ បណ្តុះបណ្តាល និងវិក្រឹត្យការ ពង្រឹងធនធាន និងបង្កើនសមត្ថភាពមុខជំនាញពិសេសវិញ្ញាសាកីឡាប្រយុទ្ធរួមនឹងឯកទេសភាសាបរទេស



- ចាត់តាំង គ្រប់គ្រង ដឹកនាំមន្ត្រី កីឡាករ-កីឡាការិនី ក្រោមឱវាទអង្គភាពអនុវត្តឱ្យបាន ត្រឹមត្រូវតាមតួនាទី និងភារកិច្ច
- ពិនិត្យ វាយតម្លៃ ដាក់ពិន្ទុ មូលវិចារណ៍ ដើម្បីស្នើសុំតែងតាំង តម្លើងឋានៈ ឋានន្តរស័ក្តិ ថ្នាក់ ផ្ទេរ-ផ្លាស់ប្តូរភារកិច្ច លើកសរសើរ ជូនរង្វាន់ ឬដាក់វិន័យដល់មន្ត្រីកីឡា កីឡាករ-កីឡាការិនីក្នុងក្របខ័ណ្ឌនគរបាល និងក្របខ័ណ្ឌមន្ត្រីរាជការស៊ីវិល ដោយអនុលោមតាមលក្ខន្តិកៈដោយឡែក និងតាមគោលការណ៍កំណត់របស់ក្រសួងមហាផ្ទៃ
- ធ្វើរបាយការណ៍បូកសរុបការងារ និងទិសដៅបន្តរបស់អង្គភាពកីឡានគរបាលជាតិតាមការកំណត់
- បំពេញភារកិច្ចផ្សេងៗទៀត ដែលអគ្គលេខាធិការប្រគល់ឱ្យ។

អង្គភាពកីឡានគរបាលជាតិកម្ពុជា មានឋានៈស្មើនាយកដ្ឋាន ដឹកនាំដោយប្រធានមួយរូប និងមានអនុប្រធានមួយចំនួនតាមការកំណត់។

**មាត្រា១០.-**

អង្គភាពបច្ចេកទេសកីឡាជំនាញ មានភារកិច្ចដូចខាងក្រោម៖
- សហការជាមួយគណៈកម្មការជាតិអូឡាំពិក និងអង្គភាពពាក់ព័ន្ធ ដើម្បីបញ្ជូនកីឡាករ-កីឡាការិនី និងគ្រូបង្វឹកទៅចូលរួមថ្នាក់ជាតិ ឬអន្តរជាតិ ក្នុងក្របខណ្ឌជាពហុកីឡា
- ពង្រឹងគុណភាពក្នុងការដឹកនាំ លើកកម្ពស់ស្មារតី ទទួលខុសត្រូវក្នុងការអភិវឌ្ឍសមត្ថភាពបច្ចេកទេស និងធនធានកីឡាចាំបាច់ត្រូវប្រកាន់ខ្ជាប់នូវក្រមសីលធម៌ និងវិជ្ជាជីវៈរបស់ខ្លួន
- គ្រប់គ្រង និងផ្លាស់ប្តូរយុត្តិសាស្ត្រនិងយុទ្ធវិធីថ្មីៗ ដោយគិតពីឧត្តមប្រយោជន៍កីឡា
- គ្រប់គ្រង និងប្រមូលផ្តុំគ្រូបង្វឹក អនុរក្សកីឡាករ-កីឡាការិនី ជម្រើសជាតិគ្រប់ប្រភេទកីឡាដើម្បីធ្វើការបំប៉នបន្ថែម និងហាត់ហ្វឹកហ្វឺនជាប្រចាំ
- ធ្វើរបាយការណ៍បូកសរុបការងារ និងទិសដៅបន្តរបស់អង្គភាពបច្ចេកទេសកីឡាតាមការកំណត់
- បំពេញភារកិច្ចផ្សេងៗទៀត ដែលអគ្គលេខាធិការដ្ឋានកីឡាប្រគល់ឱ្យ។

អង្គភាពបច្ចេកទេសកីឡា មានឋានៈស្មើនាយកដ្ឋាន ដឹកនាំដោយប្រធានមួយរូប និងមានអនុប្រធាន មួយចំនួនតាមការកំណត់។

**មាត្រា១១.-**

អង្គភាពសហប្រតិបត្តិការកីឡាអន្តរជាតិ មានភារកិច្ចដូចខាងក្រោម៖
- សហការ រៀបចំការប្រកួតជ្រើសរើសជើងឯកទូទាំងប្រទេសជាមួយសហព័ន្ធកីឡាជាតិ និងអន្តរជាតិ
- សហការជាមួយអង្គភាពពាក់ព័ន្ធលើកិច្ចការស្រាវជ្រាវ និងផ្សព្វផ្សាយស្ថិតិប្រព័ន្ធព័ត៌មានវិទ្យា និងអំពីទិន្នន័យលើវិស័យកីឡាជាតិ-អន្តរជាតិ និងតាមស្នងការដ្ឋាននគរបាលរាជធានី-ខេត្ត
- សម្របសម្រួល និងសហការជាមួយនឹងសហព័ន្ធកីឡាជាតិពាក់ព័ន្ធនឹងការងារអប់រំកាយ និងកីឡា នៅតាមរាជធានី-ខេត្ត
- សិក្សា ស្រាវជ្រាវ ពិនិត្យ និងតាមដានអំពីលទ្ធផលបច្ចេកទេសកីឡាកម្រិតខ្ពស់
- កសាងគោលនយោបាយ និងផែនការបណ្តុះបណ្តាលគ្រូអប់រំកាយកីឡាជាតិ និងគ្រូអន្តរជាតិ
- ធ្វើរបាយការណ៍បូកសរុបការងារ និងទិសដៅបន្តរបស់អង្គភាពសហប្រតិបត្តិការកីឡា អន្តរជាតិតាមការកំណត់
- បំពេញភារកិច្ចផ្សេងៗទៀត ដែលអគ្គលេខាធិការប្រគល់ឱ្យ។

អង្គភាពសហប្រតិបត្តិការកីឡាជាតិ និងអន្តរជាតិមានឋានៈស្មើនាយកដ្ឋាន ដឹកនាំដោយប្រធានមួយរូប និងមានអនុប្រធានមួយចំនួនតាមការកំណត់។

**មាត្រា១២.**_

អង្គភាពសវនកម្មផ្ទៃក្នុង មានភារកិច្ចដូចខាងក្រោម៖

- ធ្វើសវនកម្មផ្ទៃក្នុងលើការគ្រប់គ្រងហិរញ្ញវត្ថុដែលអនុវត្តតាមប្រព័ន្ធព័ត៌មានវិទ្យា ចងក្រងទិន្នន័យ កិច្ចបញ្ជីការគណនេយ្យក្នុងប្រព័ន្ធកុំព្យូទ័រ សំដៅលើការគ្រប់គ្រងឱ្យមានប្រសិទ្ធភាព
- ធ្វើសវនកម្មផ្ទៃក្នុងលើប្រសិទ្ធភាពនៃប្រព័ន្ធគ្រប់គ្រងផ្ទៃក្នុង លើការគ្រប់គ្រងហានិភ័យ ដោយឯករាជ្យគ្មានការរាំងក្នុងការត្រួតពិនិត្យបញ្ជីការគ្រប់គ្រងហិរញ្ញវត្ថុ ការគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋ និងការ គ្រប់គ្រងបញ្ជីបុគ្គលិក
- កំណត់នូវភាពសមស្រប និងការផ្តល់លទ្ធផលល្អលើប្រព័ន្ធត្រួតពិនិត្យផ្ទៃក្នុងផ្នែកគណនេយ្យរដ្ឋបាល និងកិច្ចប្រតិបត្តិការរបស់អង្គភាព
- ពិនិត្យឡើងវិញលើការគ្រប់គ្រង ការថែមទាំ ការការពារទ្រព្យសម្បត្តិ និងធ្វើការផ្ទៀងផ្ទាត់ឱ្យបានត្រឹមត្រូវ
- ពិនិត្យឡើងវិញលើប្រតិបត្តិការកម្មវិធី និងគម្រោងចំណាយអភិវឌ្ឍមូលធន ដើម្បីធានាថាលទ្ធផលស្របតាមកម្មវត្ថុ និងទិសដៅដែលបានកំណត់
- សម្របសម្រួលការងារសវនកម្មវិស័យកីឡាជាមួយនឹងសវនកម្មផ្ទៃក្នុងក្រសួង ដើម្បីធានាកិច្ចការឱ្យបានគ្រប់គ្រាន់
- ធ្វើការបណ្តុះបណ្តាលគ្រូបង្គោលពាក់ព័ន្ធនឹងការពង្រឹងចំណេះដឹង និងសមត្ថភាពលើការងារអភិបាលកិច្ចល្អ
- វាយតម្លៃផែនការ ឬសកម្មភាពកែលម្អលើចំណុចរកឃើញរបស់សវនកម្មផ្ទៃក្នុង
- ធ្វើរបាយការណ៍បូកសរុបការងារ និងទិសដៅបន្តរបស់អង្គភាពសវនកម្មផ្ទៃក្នុងតាមការកំណត់
- បំពេញភារកិច្ចផ្សេងទៀត ដែលអគ្គលេខាធិការប្រគល់ឱ្យ។

អង្គភាពសវនកម្មផ្ទៃក្នុង មានឋានៈស្មើនាយកដ្ឋាន ដឹកនាំដោយប្រធានមួយរូប និងមានអនុប្រធានមួយចំនួនតាមការកំណត់។

## ជំពូកទី៥
## ប្រភពធនធាន និងថវិកា

**មាត្រា១៣.**_

ក្រុមប្រឹក្សាកីឡាក្រសួងមហាផ្ទៃ មានប្រភពធនធានសម្រាប់ចាត់ចែងដំណើរការការងារ របស់ខ្លួនដូចខាងក្រោម៖

- ផ្គត់ផ្គង់ដោយថវិកាជាតិ ដែលជាកញ្ចប់ថវិកាដោយឡែកនៅក្នុងឧបសម្ព័ន្ធនៃកញ្ចប់ថវិកាប្រចាំឆ្នាំ របស់ក្រសួងមហាផ្ទៃ
- អំណោយពីសប្បុរសជនជាតិ និងអន្តរជាតិចូលមកក្នុងមូលនិធិកីឡាក្រសួងមហាផ្ទៃ។

## ជំពូកទី៦
## អន្តរប្បញ្ញត្តិ

**មាត្រា១៤.**_

រាល់បទប្បញ្ញត្តិទាំងឡាយណាដែលកំពុងអនុវត្ត ត្រូវបន្តសុពលភាពអនុវត្តរហូតដល់មានលិខិតបទដ្ឋានគតិយុត្តថ្មីមកជំនួស។



## ជំពូកទី៧
## អវសានប្បញ្ញត្តិ

**មាត្រា១៥.**_

អនុក្រឹត្យលេខ៥៨ អនក្រ.បក ចុះថ្ងៃទី០៤ ខែឧសភា ឆ្នាំ២០១៨ ស្តីពីការបង្កើតក្រុមប្រឹក្សាកីឡាក្រសួងមហាផ្ទៃ និងបទប្បញ្ញត្តិទាំងឡាយដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

**មាត្រា១៦.**_

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីគ្រប់ក្រសួង និងប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ អភិបាល នៃគណៈអភិបាលរាជធានី-ខេត្ត និងស្នងការ នៃស្នងការដ្ឋាននគរបាលរាជធានី-ខេត្ត ត្រូវអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃ សុក្រ ៣រោច ខែ ចេត្រ ឆ្នាំកុរ ឯកស័ក ព.ស ២៥៦៣

ធ្វើនៅរាជធានីភ្នំពេញ, ថ្ងៃទី១០ ខែ មេសា ឆ្នាំ ២០២០

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**បានយកសេចក្តីគោរពជម្រាបជូន**
**សម្តេចអគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រី**
**សូមហត្ថលេខា**
**ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ**

**សម្តេចក្រឡាហោម ស ខេង**

**កន្លែងទទួល:**
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេច ឯកឧត្តម លោកជំទាវ ឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា១៦
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងមហាផ្ទៃ
ក្រុមប្រឹក្សាកីឡាក្រសួងមហាផ្ទៃ

# រចនាសម្ព័ន្ធចាត់តាំង
# គណៈកម្មាធិការប្រតិបត្តិ ក្រុមប្រឹក្សាកីឡាក្រសួងមហាផ្ទៃ

**ប្រធាន**
**សម្តេចក្រឡាហោម ស ខេង ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ**

**អនុប្រធានទី១**
**នាយឧត្តមសេនីយ៍ សន្តិបណ្ឌិត នេត សាវឿន**

**អនុប្រធានទី២**
**ឯកឧត្តម ហ៊ុយ វណ្ណៈ**

**អនុប្រធាន**
**ឯកឧត្តម ប៊ុន ហុន**

**អនុប្រធាន**
**ឯកឧត្តម សុក ផល**

**អនុប្រធានអចិន្ត្រៃយ៍**
**នាយឧត្តមសេនីយ៍ ខៀវ សុភ័គ**

**អនុប្រធាន**
**ឯកឧត្តម ម៉ៅ ចាន់តារា**

**អនុប្រធាន**
**នាយឧត្តមសេនីយ៍ មៀច សុផាន់ណា**

**អនុប្រធាន**
អគ្គនាយក នៃអគ្គនាយកដ្ឋានរដ្ឋបាល

**អនុប្រធាន**
អគ្គនាយក នៃអគ្គនាយកដ្ឋានអត្តសញ្ញាណកម្ម

**អនុប្រធាន**
អគ្គនាយក នៃអគ្គនាយកដ្ឋានភស្តុភារ និងហិរញ្ញវត្ថុ

**អនុប្រធាន**
អគ្គនាយក នៃអគ្គនាយកដ្ឋានអន្តោប្រវេសន៍

**អនុប្រធាន**
អគ្គលេខាធិការ នៃអគ្គលេខាធិការដ្ឋាន ក្រសួងមហាផ្ទៃ

**អនុប្រធាន**
អគ្គនាយក នៃអគ្គនាយកដ្ឋានសវនកម្មផ្ទៃក្នុង

**អនុប្រធាន**
អគ្គនាយក នៃអគ្គនាយកដ្ឋានពន្ធនាគារ

**អនុប្រធាន**
ប្រធានក្រុមប្រឹក្សាធីនីកម្ម

**អនុប្រធាន**
អគ្គាធិការ នៃអគ្គាធិការដ្ឋាន

**អនុប្រធាន**
ប្រធានបណ្ឌិតសភានគរបាលជាតិកម្ពុជា

**អគ្គលេខាធិការដ្ឋាន**
**ឧត្តមសេនីយ៍ឯក បណ្ឌិត ជា ប៊ុនហេង**
**អគ្គលេខាធិការ**

**អគ្គលេខាធិការរង**

**អង្គភាព សហប្រតិបត្តិការកីឡាជាតិ-អន្តរជាតិ**
ប្រធាន : វ.ទោ ឈេង សុភ័ក្រ
អនុប្រធាន : ០៤ រូប
ការិយាល័យចំណុះ : ០៤

**អគ្គលេខាធិការរង**

**អង្គភាព បច្ចេកទេសកីឡាជំនាញ**
ប្រធាន : វ.ទោ ខូវ ប៊ុនរ័ត្ន
អនុប្រធាន : ០៤ រូប
ការិយាល័យចំណុះ : ០៤

**អគ្គលេខាធិការរង**

**អង្គភាព អង្គភាពកីឡានគរបាលជាតិ កម្ពុជា**
ប្រធាន : ឧ.ឯក ជា ប៊ុនហេង
អនុប្រធាន : ០៦ រូប
ការិយាល័យចំណុះ : ០៦

**អគ្គលេខាធិការរង**

**អង្គភាព រដ្ឋបាល - ហិរញ្ញវត្ថុ**
ប្រធាន : វ.ទោ ជា ច័ន្ទវិចិត្រ
អនុប្រធាន : ០៤ រូប
ការិយាល័យចំណុះ : ០៤

**អគ្គលេខាធិការរង**

**អង្គភាព សវនកម្មផ្ទៃក្នុង**
ប្រធាន : វ.ទោ អ៊ុ វុធ
អនុប្រធាន : ០៤ រូប
ការិយាល័យចំណុះ : ០៤

# ក្រុមប្រឹក្សាកីឡាក្រសួងមហាផ្ទៃ

## SPORT COUNCIL OF INTERIOR MINISTRY

# លក្ខន្តិកៈ

### អាណត្តិទី២

### ( ២០២០ - ២០២៤ )

# លក្ខន្តិកៈ

# ក្រុមប្រឹក្សាកីឡាក្រសួងមហាផ្ទៃ

## Sport Council of Interior Ministry

## ជំពូកទី១

## ឈ្មោះទីស្នាក់ការកណ្ដាល អាយុកាល

**ប្រការ១:** **ឈ្មោះគោលការណ៍ជាមូលដ្ឋាន**

- នៅឆ្នាំ១៩៥៩ នាសម័យសង្គមរាស្ត្រនិយម ក្រុមប្រឹក្សាកីឡាកងរាជអាវុធហត្ថ ដែលជាអង្គការកីឡាដំបូងនៃកងកម្លាំងនគរបាលជាតិ ត្រូវបានបង្កើតឡើងដោយស្នាមព្រះហស្ត សម្ដេចព្រះករុណាព្រះបាទនរោត្ដមសីហនុ ហើយពេលនោះទ្រង់ក៏ជាព្រះបិតាកីឡាជាតិ ផងដែរ។ ស្ថាប័នកីឡានេះបានចាប់បដិសន្ធិ និងកែទម្រង់ឡើងវិញ តាមរយៈសេចក្ដីសម្រេចលេខ៣៨២០សសរ ចុះថ្ងៃទី២៥ ខែវិច្ឆិកា ឆ្នាំ២០១៣ ដោយមានឈ្មោះថា សហភាពកីឡានគរបាលជាតិកម្ពុជា ដោយដំណើរការរហូតមកដល់ចុងឆ្នាំ២០១៩ ទើបត្រូវបានធ្វើវិសោធនកម្មជាថ្មី ក្នុងអាណត្តិទី២ (២០២០-២០២៤) ព្រមទាំងប្ដូរឈ្មោះមកជា **ក្រុមប្រឹក្សាកីឡាក្រសួងមហាផ្ទៃ** (អក្សរកាត់ ក.ក.ម.ផ) ជាអក្សរឡាតាំង Sport Council of Interior Ministry (S.C.I.M)។

**គោលបំណង:**

- លើកកម្ពស់វិស័យកីឡា របស់កងកម្លាំងនគរបាលជាតិ និងអភិវឌ្ឍសមត្ថភាពបច្ចេកទេសពិសេសកសាងហេដ្ឋារចនាសម្ព័ន្ធអង្គភាពកីឡា ក្នុងកងកម្លាំងនគរបាលជាតិទូទាំងប្រទេស ឲ្យមានការរីកចម្រើន ដើម្បីធ្វើសមាហរណកម្ម ចូលជាសមាជិកសហភាពកីឡានគរបាលអន្តរជាតិ International Police Sport Union "IPSU" ។

- ក្រុមប្រឹក្សាកីឡាក្រសួងមហាផ្ទៃ ជាអង្គភាពឯករាជ្យ អព្យាក្រឹត្យ មិនប្រកាន់និន្នាការនយោបាយ ដោយស្ថិតក្រោមឱវាទរបស់ក្រសួងមហាផ្ទៃ។

**ប្រការ២:** **ទីស្នាក់ការកណ្ដាល** (Head Office)

១- ទីស្នាក់ការជាផ្លូវការរបស់ក្រុមប្រឹក្សាកីឡាក្រសួងមហាផ្ទៃ ស្ថិតក្នុង **អគារមជ្ឈមណ្ឌលកីឡា** ប៉ែកខាងត្បូងអាងហែលទឹក ក្នុងពហុកីឡដ្ឋានជាតិ រាជធានីភ្នំពេញ។

E-mail: scim.org504@gmail.com

២- ទីតាំងនៃទីស្នាក់ការនេះ អាចផ្លាស់ប្ដូរទៅបាន លុះត្រាតែមានការសម្រេចរបស់រាជរដ្ឋាភិបាល ដោយយោងតាមសំណើរបស់ថ្នាក់ដឹកនាំក្រសួងមហាផ្ទៃ។

**ប្រការ៣:** **អាយុកាល** (Duration)

១- អាយុកាលនៃក្រុមប្រឹក្សាកីឡាក្រសួងមហាផ្ទៃ នេះគ្មានរយៈពេលកំណត់ (អចិន្ត្រៃយ៍)



## ជំពូកទី២

## រូបនិមិត្តសញ្ញា និងត្រា

**ប្រការ៤:** **រូបនិមិត្តសញ្ញា**

**មានរាងជារង្វង់មូល ស្ថិតនៅក្នុងខ្សែរង្វង់ពណ៌សពីរជាន់ មានវិជ្ឈមាត្រ ៩០ មីលីម៉ែត្រ**

- ផ្ទៃខ្សែរង្វង់ខាងក្រៅ: មានពណ៌ខៀវចាស់ តំណាងឲ្យភាពក្លាហាន តស៊ូ មោះមុត និងអំណត់ព្យាយាម រំលេចដោយអក្សរពណ៌ស ផ្នែកខាងលើដាក់ថា "ក្រុមប្រឹក្សាកីឡាក្រសួងមហាផ្ទៃ" និងផ្នែកខាងក្រោមអក្សរឡាតាំង "Sport Council of Interior Ministry "

- ផ្ទៃរង្វង់ខាងក្នុង: មានពណ៌ផ្ទៃមេឃតំណាងឲ្យវិសាលភាពនៃសេរីភាព និងសម្ព័ន្ធមេត្រីភាពក្នុងអង្គការកីឡាទូទាំងប្រទេស និងលើពិភពលោក។

- នៅចំកណ្ដាលនៃផ្ទៃរង្វង់ខាងក្រៅ: មានរូបរាជសីហ៍ពណ៌មាស តំណាងឲ្យកងកម្លាំងនគរបាលជាតិទូទាំងប្រទេស។

**នៅក្រោមរាជសីហ៍ មានរូបសញ្ញាកងបីប្រទាក់គ្នា ដែលក្នុងនោះ:**

- កងពណ៌ខៀវ តំណាងឲ្យកីឡាក្នុងកងកម្លាំងនគរបាលជាតិ

- កងពណ៌លឿង តំណាងឲ្យកីឡានៃយុវជនថ្នាល

- កងពណ៌ក្រហម តំណាងឲ្យកីឡាក្នុងយោធពលខេមរភូមិន្ទ

- នៅសងខាងកងទាំងបី អមទ្រព្រះនារាយណ៍ គឺជាក្បាច់ភ្ញីភ្លើង រំលេចជារូបក្បាលនាគរាជ មានពណ៌ក្រហមឆ្អិនឆ្អៅ តំណាងឲ្យកម្លាំងនៃអំណាចមហាសាល ដែលជួយទ្រទ្រង់ដល់កិច្ចអភិវឌ្ឍវិស័យកីឡា ក្នុងកងកម្លាំងនគរបាលជាតិ ឲ្យមានភាពរីកចម្រើន និងមានកិត្តិនាមល្បីរន្ទឺទូទាំងប្រទេស និងលើឆាកអន្តរជាតិ។

**ប្រការ៥:** **ត្រា** (Stamp)

ជាប្រភេទត្រាទឹកឆ្លាក់ពីស្ពាន់ មានគំរូ និងអត្ថន័យដូចគ្នាទាំងស្រុងទៅនឹងនិមិត្តសញ្ញា នៃក្រុមប្រឹក្សាកីឡាក្រសួងមហាផ្ទៃ មាន ០៣ខ្នាត កម្រិតគឺ ៖

- វិជ្ឈមាត្រ ៤១មីលីម៉ែត្រ ប្រើសម្រាប់ប្រថាប់លើលិខិតស្នាមផ្លូវការ ដែលចុះហត្ថលេខាដោយថ្នាក់ដឹកនាំគណៈកម្មាធិការប្រតិបត្តិ រួមមាន ៖ ប្រធាន អនុប្រធាន និងអគ្គលេខាធិការ។

-វិជ្ឈមាត្រ ៣៨មីលីម៉ែត្រ សម្រាប់ប្រើប្រាស់លើលិខិតស្នាមរដ្ឋបាលទូទៅ ក្នុងស្នាក់ការកណ្តាល ដែលមានអង្គភាពកីឡានគរបាលជាតិកម្ពុជា ជាតំណាងផ្លូវការ។

-វិជ្ឈមាត្រ ២៨មីលីម៉ែត្រ សម្រាប់ប្រើប្រាស់លើប័ណ្ណសម្គាល់ខ្លួនសមាជិកកីឡា (Sport License)។

| **គម្រូត្រា** | **គម្រូត្រា** | **គម្រូត្រា** |
|---|---|---|
| សម្រាប់ប្រើប្រថាប់លើលិខិតផ្លូវការ ចុះហត្ថលេខាដោយថ្នាក់ដឹកនាំក្រុមប្រឹក្សា | សម្រាប់ប្រើប្រាស់លើលិខិតស្នាម រដ្ឋបាលទូទៅក្នុងអង្គភាពកីឡា | សម្រាប់ប្រើប្រាស់លើប័ណ្ណ សម្គាល់ខ្លួនកីឡា (Sport License) |

**គំរូត្រាសមាគមកីឡា**

**ចំណុះឲ្យអង្គភាពកីឡានគរបាលជាតិកម្ពុជា**

ជាប្រភេទត្រាមូលទឹកធ្វើពីកៅស៊ូ (Rubber Stamp) មានអង្កត់ផ្ចិត ៣៦mm ទឹកត្រាពណ៌ខៀវ សម្រាប់ប្រើប្រាស់ជាបណ្តោះអាសន្នលើកិច្ចការរដ្ឋបាលរបស់សមាគមកីឡាជំនាញ។

- ក្នុងរង្វង់ផ្នែកខាងលើ : អង្គភាពកីឡានគរបាលជាតិកម្ពុជា
- ក្នុងរង្វង់ផ្នែកខាងក្រោម : ឈ្មោះសមាគមតាមប្រភេទកីឡា
  ឧ. សមាគមកីឡាវាយសី, សមាគមកីឡាប្រដាល់...។
- ផ្ទៃខាងក្នុងមានរូបរាជសីហ៍ទ្រដោយផ្កាក្បាច់ភ្ញីភ្លើង នៅសងខាងកងបី
- ខាងក្រោមរូបមានដាក់អក្សរឡាតាំងជាឈ្មោះប្រភេទកីឡានីមួយៗ

## ជំពូកទី៣

## រចនាសម្ព័ន្ធចាត់តាំង សមាជិកភាព រដ្ឋបាល និងប្រតិបត្តិការ

**ប្រការ៦** : **រចនាសម្ព័ន្ធចាត់តាំង** "តារាងឧបសម្ព័ន្ធទី១"

**ប្រការ៧** : **គណៈកម្មាធិការប្រតិបត្តិ** Executive Committee (EC)

ក្រុមប្រឹក្សាកីឡាក្រសួងមហាផ្ទៃ មានគណៈកម្មាធិការប្រតិបត្តិ ដែលមានភារកិច្ចទទួលខុសត្រូវរាល់ការងារទាំងឡាយ ប្រកបដោយស្វ័យភាពមិនចំណុះឲ្យស្ថាប័នណាមួយឡើយ ហើយសុទ្ធសឹងជា



ថ្នាក់ដឹកនាំជាន់ខ្ពស់ក្នុងកងកម្លាំងនគរបាលជាតិ និងមន្ត្រីជាន់ខ្ពស់ក្នុងរាជការស៊ីវិល ដែលក្នុងនោះរួមមាន ៖

| | |
|---|---|
| ១ - សម្តេចក្រឡាហោម **ស ខេង** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ | ប្រធាន |
| ២ - អគ្គស្នងការ នៃអគ្គស្នងការដ្ឋាននគរបាលជាតិ | អនុប្រធានទី១ |
| ៣ - រដ្ឋលេខាធិការ ទទួលបន្ទុកពត៌មាន និងកីឡា | អនុប្រធានទី២ |
| ៤ - រដ្ឋលេខាធិការ និងជានាយខុទ្ទកាល័យ រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ | អនុប្រធានអចិន្ត្រៃយ៍ |
| ៥ - រដ្ឋលេខាធិការ ក្រសួងមហាផ្ទៃ ចំនួន ០៥រូប | អនុប្រធាន |
| ៦ - អគ្គនាយក នៃអគ្គនាយកដ្ឋានរដ្ឋបាល | អនុប្រធាន |
| ៧ - អគ្គនាយក នៃអគ្គនាយកដ្ឋានភស្តុភារ និងហិរញ្ញវត្ថុ | អនុប្រធាន |
| ៨ - អគ្គនាយក នៃអគ្គនាយកដ្ឋានអត្តសញ្ញាណកម្ម | អនុប្រធាន |
| ៩ - អគ្គនាយក នៃអគ្គនាយកដ្ឋានអន្តោប្រវេសន៍ | អនុប្រធាន |
| ១០-អគ្គលេខាធិការ នៃអគ្គលេខាធិការដ្ឋាន ក្រសួងមហាផ្ទៃ | អនុប្រធាន |
| ១១-អគ្គនាយក នៃអគ្គនាយកដ្ឋានសវនកម្មផ្ទៃក្នុង | អនុប្រធាន |
| ១២-អគ្គនាយក នៃអគ្គនាយកដ្ឋានពន្ធនាគារ | អនុប្រធាន |
| ១៣-អគ្គាធិការ នៃអគ្គាធិការដ្ឋាន | អនុប្រធាន |
| ១៤-ប្រធានក្រុមប្រឹក្សានីតិកម្ម | អនុប្រធាន |
| ១៥-ប្រធានបណ្ឌិត្យសភានគរបាលជាតិកម្ពុជា | អនុប្រធាន |
| ១៦-ប្រធានអង្គភាពកីឡានគរបាលជាតិកម្ពុជា | អគ្គលេខាធិការ |
| ១៧-នាយនគរបាលជាតិជាន់ខ្ពស់ មួយចំនួន | អគ្គលេខាធិការរង |
| ១៨-អភិបាល នៃគណៈអភិបាលរាជធានី-ខេត្ត | សមាជិក |
| ១៩-ប្រធាននាយកដ្ឋាន និងអង្គភាព ចំណុះក្រសួងមហាផ្ទៃ | សមាជិក |
| ២០-ស្នងការ នៃស្នងការដ្ឋាននគរបាលរាជធានី-ខេត្ត | សមាជិក |

គណៈកម្មាធិការប្រតិបត្តិ អាចតែងតាំងគណៈកម្មការ ដើម្បីជាជំនួយក្នុងការដោះស្រាយបញ្ហាជាក់ស្តែងតាមការចាត់តាំងរបស់ប្រធានគណៈកម្មាធិការប្រតិបត្តិ។

**ប្រការ៨** : **សមាជិកប្រតិបត្តិ** Executive Members (EM) ជាកម្លាំងជម្រុញជួយដល់ដំណើរការដឹកនាំរបស់គណៈកម្មាធិការប្រតិបត្តិ (EC) ដែលរួមមាន ៖

១- ប្រធាន គ្រប់នាយកដ្ឋាន-អង្គភាព ចំណុះក្រសួងមហាផ្ទៃ

២- ស្នងការ គ្រប់ស្នងការដ្ឋាននគរបាលរាជធានី-ខេត្ត

៣- សមាជិកភាពនេះ នឹងត្រូវបាត់បង់ជាស្វ័យប្រវត្តិក្នុងករណីផ្ទេរមុខតំណែង ចូលនិវត្តន៍ លាលែងពីការងារ ... ហើយត្រូវបានជំនួសវិញ ដោយអ្នកចូលកាន់តំណែងថ្មី ជាស្វ័យប្រវត្តិ។

**ប្រការ៩ : សមាជិកទ្រទ្រង់** (Supported Member)

១- កងកម្លាំងនគរបាលជាតិ គ្រប់លំដាប់ថ្នាក់ទូទាំងប្រទេស និងថ្នាក់ដឹកនាំ មន្ត្រីរាជការស៊ីវិលទាំងថ្នាក់ជាតិ-ថ្នាក់ក្រោមជាតិ។

២- សមាជិកម្នាក់ៗ ត្រូវជួយឧបត្ថម្ភថវិកាដោយស្ម័គ្រចិត្ត ចំនួន ២,០០០រៀល ក្នុងមួយខែ

៣- ថវិកាទាំងនេះត្រូវបញ្ចូលទៅក្នុងមូលនិធិកីឡា (Sport Fund) ដែលនឹងចូលរួមវិភាគទានក្នុងការងារកសាងហេដ្ឋារចនាសម្ព័ន្ធនានា សំដៅបម្រើផលប្រយោជន៍វិស័យកីឡាយូរអង្វែង។

**ប្រការ១០ : រចនាសម្ព័ន្ធ និងប្រតិបត្តិការ**

**អគ្គលេខាធិការដ្ឋាន នៃក្រុមប្រឹក្សាកីឡាក្រសួងមហាផ្ទៃ** ត្រូវបានបំពេញបន្ថែម ដើម្បីទទួលភារកិច្ចធ្វើជាសេនាធិការ ឲ្យក្រសួងមហាផ្ទៃ ដឹកនាំដោយអគ្គលេខាធិការមួយរូប មានឋានៈ និងបុព្វសិទ្ធិស្មើអគ្គនាយក និងមានអគ្គលេខាធិការរងមួយចំនួន ជាជំនួយការ មានឋានៈ និងបុព្វសិទ្ធិស្មើអគ្គនាយករងនានា ចំណុះក្រសួងមហាផ្ទៃ ។

អគ្គលេខាធិការដ្ឋាន នៃក្រុមប្រឹក្សាកីឡាក្រសួងមហាផ្ទៃ មានភារកិច្ចក្នុងការគ្រប់គ្រង ដឹកនាំជំរុញការអភិវឌ្ឍវិស័យកីឡា និងលើកទិសដៅផែនការយុទ្ធសាស្ត្រ ធានាបាននូវស្ថេរភាព និងការរីកចម្រើនខាងវិស័យកីឡាក្នុងកងកម្លាំងនគរបាលជាតិ ទូទាំងប្រទេស ។

អគ្គលេខាធិការ និងអគ្គលេខាធិការរង នៃក្រុមប្រឹក្សាកីឡាក្រសួងមហាផ្ទៃ ត្រូវតែងតាំងដោយព្រះរាជក្រឹត្យ ឬអនុក្រឹត្យ តាមសំណើរបស់ប្រធាន ។

តួនាទី ភារកិច្ច និងរចនាសម្ព័ន្ធ របស់អគ្គលេខាធិការដ្ឋាន នៃក្រុមប្រឹក្សាកីឡាក្រសួងមហាផ្ទៃ ត្រូវកំណត់ដោយអនុក្រឹត្យរបស់រាជរដ្ឋាភិបាល ។

១-អង្គភាពរដ្ឋបាល - ហិរញ្ញវត្ថុ មានតួនាទី ធ្វើជាសេនាធិការ ជូនអគ្គលេខាធិការដ្ឋាន នៃក្រុមប្រឹក្សាកីឡាក្រសួងមហាផ្ទៃ ដែលមានភារកិច្ច ដូចខាងក្រោម ៖

- សម្របសម្រួលសកម្មភាពការងារ របស់អគ្គលេខាធិការដ្ឋានកីឡា និងអង្គភាពនានាក្រោមឱវាទ
- ធានាប្រសិទ្ធិភាព នូវដំណើរការការងាររដ្ឋបាល និងរៀបចំផែនការហិរញ្ញវត្ថុ របស់អគ្គលេខាធិការដ្ឋាន
- បញ្ជូន និងរក្សាទុកលិខិតស្នាម ឯកសារនានា តាមបញ្ជារបស់អគ្គលេខាធិការដ្ឋានកីឡា ឲ្យទាន់ពេលវេលា ធានាគង់វង្ស និងសម្ងាត់
- ធ្វើការងារបុគ្គលិក ភស្តុភារ គណនេយ្យ និងបញ្ជីសារពើភណ្ឌ ទ្រព្យសម្បត្តិរដ្ឋ របស់អគ្គលេខាធិការដ្ឋាន
- គ្រប់គ្រង និងផ្គត់ផ្គង់មធ្យោបាយសម្ភារៈរដ្ឋបាល សម្រាប់ឲ្យអគ្គលេខាធិការដ្ឋានកីឡា ដំណើរការប្រកបដោយនិរន្តរភាព និងប្រសិទ្ធភាព
- លើកគម្រោងថវិកាប្រចាំឆ្នាំរបស់អគ្គលេខាធិការដ្ឋាន
- លើកគម្រោងប្រេងឥន្ធនៈ ប្រចាំខែ ត្រីមាស និងប្រចាំឆ្នាំ របស់ថ្នាក់ដឹកនាំអគ្គលេខាធិការដ្ឋាន និងអង្គភាពចំណុះ
- រៀបចំបែបបទ និងសំណើផ្តល់មេដាយការងារ និងគ្រឿងឥស្សរិយយសផ្សេងៗជូនថ្នាក់



ដឹកនាំ និងមន្ត្រីក្រោមឱវាទ
- ធ្វើរបាយការណ៍បូកសរុបការងារ និងទិសដៅបន្តរបស់អង្គភាពរដ្ឋបាលវត្ថុ តាមការកំណត់ហិរញ្ញ-
- ទទួលអនុវត្តភារកិច្ចផ្សេងៗទៀត ដែលអគ្គលេខាធិការដ្ឋានប្រគល់ឲ្យ

អង្គភាពរដ្ឋបាល - ហិរញ្ញវត្ថុ មានឋានៈស្មើនាយកដ្ឋាន ដឹកនាំដោយប្រធាន មួយរូប និងមានអនុប្រធាន មួយចំនួន តាមការកំណត់ ។

**២-អង្គភាពកីឡានគរបាលជាតិកម្ពុជា មានតួនាទី ធ្វើជាសេនាធិការជូនអគ្គលេខាធិការដ្ឋាន នៃក្រុមប្រឹក្សាកីឡាក្រសួងមហាផ្ទៃ លើកិច្ចការជំនាញ ដែលមានភារកិច្ច ដូចខាងក្រោម ៖**

- កសាងផែនការយុទ្ធសាស្ត្រ ពង្រឹងការគ្រប់គ្រង ដឹកនាំ ដើម្បីអភិវឌ្ឍលើគ្រប់វិស័យកីឡាក្រោមឱវាទក្រសួងមហាផ្ទៃ ឲ្យមានការរីកចម្រើនឆាប់រហ័ស
- ផ្សព្វផ្សាយ អប់រំ ដល់មន្ត្រីរាជការស៊ីវិល កងកម្លាំងនគរបាលជាតិ ឲ្យយល់ជ្រួតជ្រាបពីអត្ថប្រយោជន៍ នៃការហ្វឹកហាត់កីឡា ដើម្បីសុខភាព និងសាមគ្គីភាព
- ទំនាក់ទំនង សហការជាមួយអង្គភាពក្រៅរដ្ឋាភិបាល អង្គការជាតិ អន្តរជាតិ ក្រុមហ៊ុន និងសប្បុរសជនក្នុងការស្វែងរកជំនួយនានា សម្រាប់ទ្រទ្រង់កីឡា ដើម្បីកសាងឲ្យបាននៅហេដ្ឋារចនាសម្ព័ន្ធនានា សំដៅបម្រើឲ្យការហ្វឹកហាត់យូរអង្វែង
- លើកគម្រោងសាងសង់ ជួសជុលពង្រីកទីតាំងដែលមានស្រាប់ ឬទីតាំងថ្មី សម្រាប់ហ្វឹកហាត់លើគ្រប់វិញ្ញាសា ឲ្យមានលក្ខណៈសម្បត្តិអាចធ្វើជាម្ចាស់ផ្ទះ ក្នុងការរៀបចំប្រកួតជាលក្ខណៈអន្តរជាតិបាន
- កសាងផែនការបណ្តុះបណ្តាល និងវិក្រឹត្យការ ពង្រឹងធនធាន និងបង្កើនសមត្ថភាពមុខជំនាញ ពិសេសវិញ្ញាសាកីឡាប្រយុទ្ធ រួមនឹងឯកទេសភាសាបរទេស
- ចាត់តាំងគ្រប់គ្រង ដឹកនាំមន្ត្រី កីឡាករ កីឡាការិនី ក្រោមឱវាទអង្គភាពអនុវត្តឲ្យបានត្រឹមត្រូវតាមតួនាទី ភារកិច្ច
- ពិនិត្យវាយតម្លៃ ដាក់ពិន្ទុ មូលវិចារណ៍ ដើម្បីស្នើសុំតែងតាំង តម្លើងឋានៈ ឋានន្តរស័ក្តិ ថ្នាក់ផ្ទេរផ្លាស់ប្តូរភារកិច្ច លើកសរសើរជូនរង្វាន់ ដាក់វិន័យដល់មន្ត្រីកីឡា កីឡាករ កីឡាការិនីក្នុងក្របខ័ណ្ឌនគរបាល ក្របខ័ណ្ឌមន្ត្រីរាជការស៊ីវិល អនុលោមតាមលក្ខន្តិកៈដោយឡែក និងតាមគោលការកំណត់របស់ក្រសួងមហាផ្ទៃ
- ធ្វើរបាយការណ៍បូកសរុបការងារ និងទិសដៅបន្តរបស់អង្គភាពកីឡានគរបាលជាតិតាមការកំណត់
- ទទួលអនុវត្តភារកិច្ចផ្សេងៗទៀត ដែលអគ្គលេខាធិការដ្ឋានប្រគល់ឲ្យ
- មានភារកិច្ចដឹកនាំ ណែនាំអនុវត្តន៍ នូវរាល់បណ្តាសកម្មភាពទាក់ទងនឹងវិស័យកីឡាក្នុងកងកម្លាំងនគរបាលជាតិទូទាំងប្រទេស។
- គ្រប់បណ្តាសមាគម ក្លឹបកីឡាទាំងអស់ក្នុងកម្លាំងនគរបាលជាតិ និងមន្ត្រីរាជការស៊ីវិលក្រសួងមហាផ្ទៃ ត្រូវស្ថិតក្រោមការដឹកនាំផ្ទាល់របស់អង្គភាពកីឡានៃក្រុមប្រឹក្សាកីឡាក្រសួងមហាផ្ទៃ។
- អង្គភាពគ្រប់គ្រងកីឡា មានរចនាសម្ព័ន្ធដឹកនាំដោយឡែក និងអនុវត្តន៍ការងារប្រហាក់ប្រហែលទៅនឹង នាយកដ្ឋាននានាចំណុះក្រសួងមហាផ្ទៃ។

អង្គភាពកីឡានគរបាលជាតិ កម្ពុជា មានឋានៈស្មើនាយកដ្ឋាន ដឹកនាំដោយប្រធាន មួយរូប និងមានអនុប្រធាន មួយចំនួន តាមការកំណត់ ។

៣-អង្គភាពបច្ចេកទេសកីឡាជំនាញ មានតួនាទីធ្វើជាសេនាធិការ ជូនអគ្គលេខាធិការដ្ឋាន នៃក្រុមប្រឹក្សាកីឡាក្រសួងមហាផ្ទៃ ដែលមានភារកិច្ច ដូចខាងក្រោម ៖

- សហការជាមួយគណៈកម្មការជាតិអូឡាំពិក និងអង្គភាពពាក់ព័ន្ធ ដើម្បីបញ្ជូនកីឡាករ កីឡា ការិនី និងគ្រូបង្វឹកទៅចូលរួមថ្នាក់ជាតិ អន្តរជាតិ ក្នុងក្របខណ្ឌជាពហុកីឡា
- ពង្រឹងគុណភាពក្នុងការដឹកនាំ លើកកម្ពស់ស្មារតីទទួលខុសត្រូវ ក្នុងការអភិវឌ្ឍសមត្ថភាពបច្ចេកទេស និងធនធានកីឡា ចាំបាច់ត្រូវប្រកាន់ខ្ជាប់នូវក្រមសីលធម៌ វិជ្ជាជីវៈរបស់ខ្លួន
- គ្រប់គ្រង និងផ្លាស់ប្តូរយុត្តិសាស្ត្រ និងយុទ្ធវិធីថ្មីៗ ដោយគិតពីឧត្តមប្រយោជន៍កីឡា
- គ្រប់គ្រង និងប្រមូលផ្តុំគ្រូបង្វឹក អនុរក្សកីឡាករ កីឡាការិនី ជម្រើសជាតិ គ្រប់ប្រភេទកីឡា ដើម្បីធ្វើការបំប៉នបន្ថែម និងហាត់ហ្វឹកហ្វឺនជាប្រចាំ
- ធ្វើរបាយការណ៍បូកសរុបការងារ និងទិសដៅបន្តរបស់អង្គភាពបច្ចេកទេសកីឡាតាមការកំណត់
- ទទួលអនុវត្តភារកិច្ចផ្សេងៗទៀត ដែលអគ្គលេខាធិការដ្ឋានកីឡាប្រគល់ឲ្យ

អង្គភាពបច្ចេកទេសកីឡា មានឋានៈស្មើនាយកដ្ឋាន ដឹកនាំដោយប្រធាន មួយរូប និងមានអនុប្រធាន មួយចំនួន តាមការកំណត់ ។

៤-អង្គភាពសហប្រតិបត្តិការកីឡាជាតិ-អន្តរជាតិ មានតួនាទី ធ្វើជាសេនាធិការជូនអគ្គលេខា ធិការដ្ឋាន នៃក្រុមប្រឹក្សាកីឡាក្រសួងមហាផ្ទៃ ដែលមានភារកិច្ច ដូចខាងក្រោម ៖

- សហការរៀបចំ ការប្រកួតជ្រើសរើសជើងឯកទូទាំងប្រទេស ជាមួយសហព័ន្ធកីឡាជាតិ និងអន្តរជាតិ
- សហការជាមួយអង្គភាពពាក់ព័ន្ធលើកិច្ចការស្រាវជ្រាវ និងផ្សព្វផ្សាយស្ថិតិប្រព័ន្ធព័ត៌មានវិទ្យា និងអំពីទិន្នន័យលើវិស័យកីឡាជាតិ អន្តរជាតិ និងតាមស្នងការដ្ឋាននគរបាលរាជធានី-ខេត្ត
- សម្របសម្រួល និងសហការជាមួយនឹងសហព័ន្ធកីឡាជាតិ ពាក់ព័ន្ធនឹងការងារអប់រំកាយ និងកីឡា នៅតាមរាជធានី-ខេត្ត
- សិក្សាស្រាវជ្រាវ ពិនិត្យ និងតាមដានអំពីលទ្ធផលបច្ចេកទេសកីឡាកម្រិតខ្ពស់
- កសាងគោលនយោបាយ និងផែនការបណ្តុះបណ្តាលគ្រូអប់រំកាយកីឡាជាតិ និងគ្រូអន្តរជាតិ
- ធ្វើរបាយការណ៍បូកសរុបការងារ និងទិសដៅបន្តរបស់អង្គភាពសហប្រតិបត្តិការកីឡាជាតិ-អន្តរជាតិតាមការកំណត់
- ទទួលអនុវត្តភារកិច្ចផ្សេងៗទៀត ដែលអគ្គលេខាធិការដ្ឋានប្រគល់ឲ្យ

អង្គភាពសហប្រតិបត្តិការកីឡាជាតិ-អន្តរជាតិ មានឋានៈស្មើនាយកដ្ឋាន ដឹកនាំដោយប្រធាន មួយរូប និងមានអនុប្រធាន មួយចំនួន តាមការកំណត់ ។

៥-អង្គភាពសវនកម្មផ្ទៃក្នុង មានតួនាទី ធ្វើសេនាធិការជូនអគ្គលេខាធិការដ្ឋាន នៃក្រុមប្រឹក្សាកីឡាក្រសួងមហាផ្ទៃ ដែលមានភារកិច្ច ដូចខាងក្រោម ៖

- ធ្វើសវនកម្មផ្ទៃក្នុងលើការគ្រប់គ្រងហិរញ្ញវត្ថុ ដែលអនុវត្តតាមប្រព័ន្ធព័ត៌មានវិទ្យា ចងក្រងទិន្នន័យកិច្ចបញ្ជីការគណនេយ្យក្នុងប្រព័ន្ធកុំព្យូទ័រ សំដៅលើការគ្រប់គ្រងឲ្យមានប្រសិទ្ធភាព
- ធ្វើសវនកម្មផ្ទៃក្នុងលើប្រសិទ្ធភាព នៃប្រព័ន្ធគ្រប់គ្រងផ្ទៃក្នុង លើការគ្រប់គ្រងហានិភ័យដោយឯករាជ គ្មានការរារាំងក្នុងការត្រួតពិនិត្យបញ្ជីការគ្រប់គ្រងហិរញ្ញវត្ថុ ការគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋ និងការគ្រប់គ្រងបញ្ជីបុគ្គលិក



- កំណត់នូវភាពសមស្រប និងការផ្តល់លទ្ធផលល្អ លើប្រព័ន្ធត្រួតពិនិត្យផ្ទៃក្នុងផ្នែកគណនេយ្យ រដ្ឋបាល និងកិច្ចប្រតិបត្តិការរបស់អង្គភាព
- ពិនិត្យឡើងវិញលើការគ្រប់គ្រង ការថែមទាំ ការការពារទ្រព្យសម្បត្តិ និងធ្វើការផ្ទៀងផ្ទាត់ឲ្យបានត្រឹមត្រូវ
- ពិនិត្យឡើងវិញលើប្រតិបត្តិការកម្មវិធី និងគម្រោងចំណាយអភិវឌ្ឍមូលធន ដើម្បីធានាថាលទ្ធផលស្របតាមកម្មវត្ថុ និងទិសដៅដែលបានកំណត់
- សម្របសម្រួលការងារសវនកម្មវិស័យកីឡា ជាមួយនឹងសវនកម្មផ្ទៃក្នុងក្រសួង ដើម្បីធានាកិច្ចការឲ្យបានគ្រប់គ្រាន់
- ធ្វើការបណ្តុះបណ្តាលគ្រូបង្គោល ពាក់ព័ន្ធនឹងការពង្រឹងចំណេះដឹង និងសមត្ថភាពលើការងារ អភិបាលកិច្ចល្អ
- វាយតម្លៃផែនការ ឬសកម្មភាពកែលម្អរ លើចំណុចរកឃើញរបស់សវនកម្មផ្ទៃក្នុង
- ធ្វើរបាយការណ៍បូកសរុបការងារ និងទិសដៅបន្តរបស់អង្គភាពសវនកម្មផ្ទៃក្នុងតាមការកំណត់
- ទទួលអនុវត្តភារកិច្ចផ្សេងៗទៀត ដែលអគ្គលេខាធិការដ្ឋានប្រគល់ឲ្យ

អង្គភាពសវនកម្មផ្ទៃក្នុង មានឋានៈស្មើនាយកដ្ឋាន ដឹកនាំដោយប្រធាន មួយរូប និងមានអនុប្រធាន មួយចំនួន តាមការកំណត់ ។

- ការប្រើប្រាស់ត្រា (Rubber Stamp) តាមគំរូឯកភាពគ្នាគ្រប់សមាគមចំណុះកំណត់ដោយក្រុមប្រឹក្សាកីឡាក្រសួងមហាផ្ទៃ លើរាល់លិខិតស្នាមរដ្ឋបាលដែលមានទំនាក់ទំនងទៅនឹងអង្គភាពពាក់ព័ន្ធនានា ។

- ដោយឡែកសិទ្ធិ និងភារកិច្ចផ្សេងទៀត ត្រូវបានកំណត់ជាក់ស្តែង ដោយក្រុមប្រឹក្សាកីឡាក្រសួងមហាផ្ទៃ តាមសំណើរបស់អង្គភាពកីឡានគរបាលជាតិកម្ពុជា ។

## ជំពូកទី៤
## អង្គមហាសន្និបាត និងគណៈកម្មាធិការ

**ប្រការ១១ : អង្គមហាសន្និបាត**

១- អង្គមហាសន្និបាត ត្រូវប្រារព្ធធ្វើឡើងរៀងរាល់ពីរឆ្នាំម្តង នៅមុនបញ្ចប់រយៈពេល ៣/៤ នៃឆ្នាំទី៤ ដែលជាឆ្នាំចុងក្រោយ។

២- ប្រតិភូចូលរួមក្នុងអង្គមហាសន្និបាត រួមមាន សមាជិកប្រតិបត្តិសមាគមនីមួយៗ ដែលចំណុះក្រុមប្រឹក្សាកីឡាក្រសួងមហាផ្ទៃ (SCIM) និងសមាជិកនៃគណៈកម្មាធិការប្រតិបត្តិរបស់ក្រុមប្រឹក្សា។

៣- ប្រតិភូនីមួយៗ ត្រូវតែងតាំងជាលាយលក្ខណ៍អក្សរពីប្រធានសាមីរបស់ខ្លួន ហើយបញ្ជូនទៅអគ្គលេខាធិការ ក្រុមប្រឹក្សាកីឡាក្រសួងមហាផ្ទៃ (SCIM) មុនពេលបើកអង្គមហាសន្និបាត។

៤- ប្រតិភូនៃសមាជិកសមាគមមួយ មានសិទ្ធិបោះឆ្នោតមួយសម្លេង និងអាចតំណាងត្រឹមតែសមាគមរបស់ខ្លួនប៉ុណ្ណោះ។

៥- សមាជិកនីមួយៗ នៃគណៈកម្មាធិការប្រតិបត្តិ មានសម្លេងបោះឆ្នោតមួយ ។

របៀបវារៈនៃអង្គមហាសន្និបាត ត្រូវបញ្ចូលការងារសំខាន់ៗ ដូចខាងក្រោម ៖

១- ការត្រួតពិនិត្យទៅលើអាណត្តិនីមួយៗ

២- ការគាំពារសមាជិកសមាគម និងការពារការបោះឆ្នោត

៣- ការត្រួតពិនិត្យ និងអនុម័តលើកំណត់ហេតុ នៃអង្គមហាសន្និបាតលើកមុន

៦- របាយការណ៍ស្តីពីការងារនៃឆ្នាំកន្លងមក របស់គណៈកម្មាធិការប្រតិបត្តិ ដែលត្រូវធ្វើបទបង្ហាញដោយប្រធាន ឬ អនុប្រធាន។

៧- របាយការណ៍ស្តីពីការងាររបស់អគ្គលេខាធិការ និងសកម្មភាពកីឡាថ្នាក់ជាតិ ព្រមទាំងការងាររបស់គណៈកម្មាធិការបច្ចេកទេស។

៨- របាយការណ៍ហិរញ្ញវត្ថុ ដែលរៀបចំឡើងដោយប្រធានគណនេយ្យ (CA) នៃអង្គភាពកីឡានគរបាលជាតិកម្ពុជា និងរបាយការណ៍សវនកម្ម។

៩- ការបោះឆ្នោតជ្រើសរើសសមាជិក នៃគណៈកម្មាធិការប្រតិបត្តិ គណៈកម្មាធិការបច្ចេកទេស និងគណៈកម្មាធិការសវនកម្ម។

១០- ការពិភាក្សា និងការបញ្ចេញមតិ ទៅលើលិខិតបទដ្ឋានផ្សេងៗ

១១- សំណើថវិកាសម្រាប់រយៈពេល ០៤ឆ្នាំ ខាងមុខទៀត និងការកំណត់នូវថវិកាសមាជិកភាព

១២- ការរៀបចំប្រតិទិនការប្រកួតជ្រើសរើសជើងឯក

១៣- ការតែងតាំងអ្នកទទួលខុសត្រូវរៀបចំ នៃអង្គមហាសន្និបាតលើកក្រោយទៀត

១៤- បញ្ហាផ្សេងៗ

**ប្រការ១២ : អង្គប្រជុំវិសាមញ្ញ និងទស្សនៈផ្សេងៗ**

១- អង្គប្រជុំវិសាមញ្ញនឹងត្រូវបានកោះប្រជុំ ប្រសិនបើសមាជិកពាក់កណ្តាល នៃសមាគមទាំងអស់ ដាក់ពាក្យស្នើសុំទៅអគ្គលេខាធិការ ដោយមានការអះអាងពីហេតុផលជាលាយលក្ខណ៍អក្សរ និងប្រកាសពីធន្ទះរបស់ខ្លួន។ ប្រធានត្រូវសម្រេចចិត្តអំពីទីតាំង និងកាលបរិច្ឆេទ នៃអង្គមហាសន្និបាតក្នុងរយៈពេលបីខែ បន្ទាប់ពីទទួលបានសំណើសមាជិកសមាគម នឹងទទួលបានព័ត៌មានអំពីកាលបរិច្ឆេទ និងទីតាំង យ៉ាងហោចណាស់បីសប្តាហ៍ មុនពេលអង្គមហាសន្និបាតប្រារព្ធឡើង។ ក្នុងករណីនេះការសម្រេចចិត្តទៅលើសំណួរសំខាន់ៗនឹងត្រូវធ្វើឡើង នៅមុខអង្គមហាសន្និបាត ដែលត្រូវប្រារព្ធឡើងជាទៀងទាត់នាពេលក្រោយទៀត។ ប្រធាន អគ្គលេខាធិការ និងអគ្គហិរញ្ញិក អាចរៀបចំអង្គប្រជុំវិសាមញ្ញរួមគ្នា ដោយប្រកាសភ្លាមៗទៅសមាជិកសមាគមម្នាក់ៗ ។

២- អង្គប្រជុំវិសាមញ្ញ សម្រេចចិត្តត្រឹមតែបញ្ហា ដែលមាននៅក្នុងរបៀបវារៈរបស់ខ្លួនតែប៉ុណ្ណោះ (អង្គប្រជុំវិសាមញ្ញ អាចសម្រេចចិត្តរំលាយសមាគម និងបង្កើតថ្មីបាន)។

៣- អង្គប្រជុំវិសាមញ្ញ មានសិទ្ធិដើម្បីទទួលនូវការសម្រេចនៅក្នុងអាណត្តិទី១ ដែលមានវត្តមានបុគ្គលដែលមានសិទ្ធិបោះឆ្នោត យ៉ាងហោចណាស់ក៏ពាក់កណ្តាលដែរ។ ក្នុងអាណត្តិទី២ ចំនួននៃបុគ្គលដែលមានវត្តមាន នឹងមិនត្រូវបានពិចារណាដរាបណាទស្សនបន្ថែមលើលក្ខន្តិកៈ មិនត្រូវបានថ្លែងដាច់ដោយឡែកពីគ្នា។

៤- ការសម្រេចចិត្តត្រូវធ្វើឡើងតាមរយៈសម្លេង ២/៣ ឬ ៣/៤ ក្នុងករណីរំលាយសមាគម

៥- ការបោះឆ្នោត ត្រូវធ្វើដោយការលើកដៃ ដរាបណាបុគ្គល ១/៤ នៃបុគ្គលមានសិទ្ធបោះឆ្នោតដែលមានវត្តមាន មិនបានស្នើសុំនូវការបោះឆ្នោតជាការសម្ងាត់នោះទេ។

៦- ប្រធាន ធ្វើជាអធិបតីរាល់កិច្ចប្រជុំកំពូល នៃអង្គមហាសន្និបាត។ ក្នុងករណីអវត្តមានអង្គមហាសន្និបាតនឹងត្រូវធ្វើជាអធិបតីដោយអនុប្រធានទី១។ ប្រសិនបើអនុប្រធានទី១ មិនអាចចូលរួមបាន អង្គមហាសន្និបាតត្រូវជ្រើសរើសគណៈកម្មាធិការប្រតិបត្តិ ០១រូប តាមឋានានុក្រមក្នុងចំណោមបេក្ខជនចូលរួមធ្វើអធិបតី ដឹកនាំកិច្ចប្រជុំកំពូល។

**ប្រការ១៣ : គណៈកម្មាធិការបច្ចេកទេស គណៈកម្មាធិការសវនកម្ម និងអង្គភាពកីឡា**

១- គណៈកម្មាធិការបច្ចេកទេស (TC) គឺជាផ្នែកមួយអចិន្ត្រៃយ៍ របស់អង្គភាពកីឡានគរបាលជាតិកម្ពុជា (NPSUC)។ គណៈកម្មាធិការបច្ចេកទេស ទទួលខុសត្រូវក្នុងការបង្កើត និងកែលម្អនូវច្បាប់នៃការប្រកួតទៅតាមកម្រិតវិន័យ របស់ប្រភេទកីឡានីមួយៗ ដែលត្រូវអនុវត្តក្នុងក្រុមប្រឹក្សាកីឡាក្រសួងមហាផ្ទៃ។

- ការកែសម្រួលច្បាប់នៃការប្រកួត ត្រូវស្នើដោយគណៈកម្មាធិការបច្ចេកទេស គឺមានសុពលភាពជាបណ្តោះអាសន្ន រហូតអង្គមហាសន្និបាតលើកក្រោយសម្រេចទទួលយក។

- គណៈកម្មាធិការបច្ចេកទេស មានអគ្គលេខាធិការ ជាតំណាងរបស់ប្រធាន ដើម្បីឲ្យស្របតាមស្តង់ដាអន្តរជាតិ គួរបង្កើតឲ្យមាន ការិយាល័យជើងឯកនគរបាលជាតិ ពោលគឺប្រធានដែលចាត់ចែងកម្រិតបទបញ្ជា និងប្រភេទកីឡានីមួយៗ។

២- គណៈកម្មាធិការសវនកម្ម (AC) គឺជាស្ថាប័នអចិន្ត្រៃយ៍ និងឯករាជ្យ ដែលត្រួតពិនិត្យលើសកម្មភាពច្បាប់ និងហិរញ្ញវត្ថុ របស់អង្គភាពកីឡានគរបាលជាតិកម្ពុជា (NPSUC) គណៈកម្មាធិការសវនកម្ម មានប្រធានមួយ និងសមាជិកមួយចំនួន តាមស្ថានភាពជាក់ស្តែង។

៣- អង្គភាពកីឡា គឺជាស្ថាប័នអចិន្ត្រៃយ៍ និងឯករាជ្យរបស់ក្រុមប្រឹក្សាកីឡាក្រសួងមហាផ្ទៃ (SCIM)។ អង្គភាពកីឡាមានរូបវន្តបុគ្គល និងអង្គភាពច្បាប់ ដែលនឹងប្រកាសនូវជំនួយហិរញ្ញវត្ថុ ឬ ការឧបត្ថម្ភផ្សេងៗ សម្រាប់ការរីកចម្រើននៃសកម្មភាពរបស់ក្រុមប្រឹក្សាកីឡាក្រសួងមហាផ្ទៃ។ រចនាសម្ព័ន្ធរបស់អង្គភាពកីឡា ត្រូវបានទទួលស្គាល់ដោយប្រកាស របស់ក្រសួងមហាផ្ទៃ។

៤- ប្រធានអង្គភាពកីឡា មានសិទ្ធិពេញលេញ ក្នុងការចូលរួមគ្រប់សកម្មភាពការងារទាំងអស់របស់គណៈកម្មាធិការប្រតិបត្តិ និងស្ថាប័នប្រតិបត្តិផ្សេងៗ របស់ក្រុមប្រឹក្សាកីឡាក្រសួងមហាផ្ទៃ ព្រមទាំងអាចចូលរួមនៅក្នុងអង្គមហាសន្និបាត និងលើកឡើងជាមតិណែនាំបាន។

## ជំពូកទី៥
## ប្រភពធនធាន និងគណនេយ្យ

**ប្រការ១៤ : ប្រភពធនធាន និងគណនេយ្យ**

១- ប្រភពធនធានប្រចាំឆ្នាំ របស់ក្រុមប្រឹក្សាកីឡាក្រសួងមហាផ្ទៃ (SCIM)

- ការបង់ប្រាក់សមាជិកភាព របស់សមាជិកម្នាក់ៗ
- ការបង់សិទ្ធិចុះឈ្មោះចូលរួមប្រកួតជើងឯក ក្នុងក្របខ័ណ្ឌនគរបាលជាតិ (NC) និងការចំណាយផ្សេងៗ លើការប្រកួតដោយសហព័ន្ធ។
- ថវិកាដែលបានមកពីការលក់ផលិតផល
- ការឧបត្ថម្ភពីក្រុមប្រឹក្សាកីឡាអន្តរជាតិ របស់សហភាពកីឡានគរបាលអន្តរជាតិ និងឧបការីជនផ្សេងៗទៀត។
- ការទទួលខុសត្រូវ នៃកិច្ចសន្យាដែលត្រូវធ្វើឡើងដោយយកកម្រៃ

២- រូបិយវត្ថុ ត្រូវលើកឡើងជាប្រាក់រៀល

៣- ហិរញ្ញវត្ថុប្រចាំឆ្នាំរបស់ក្រុមប្រឹក្សាកីឡាក្រសួងមហាផ្ទៃ (SCIM) ត្រូវឆ្លើយតបទៅនឹងប្រតិទិនការងារប្រចាំឆ្នាំ (តុល្យភាពចំណូល-ចំណាយ) គណៈកម្មាធិការសវនកម្ម ត្រួតពិនិត្យទៀងទាត់ ឬ ត្រួតពិនិត្យនៅចុងឆ្នាំនីមួយៗនូវឯកសារហិរញ្ញវត្ថុ របាយការណ៍របស់អគ្គហិរញ្ញិក និងឯកសារពាក់ព័ន្ធទៅនឹងការដឹកនាំសកម្មភាពហិរញ្ញវត្ថុ ដែលធ្វើឡើងដោយអង្គភាពគ្រប់គ្រងកីឡា របស់ក្រុមប្រឹក្សាកីឡាក្រសួងមហាផ្ទៃ។

៤- ក្នុងពេលសវនកម្មម្តងៗ ត្រូវចូលរួមដោយសវនករ ពីររូប ដែលតែងតាំងដោយគណៈកម្មាការប្រតិបត្តិ។

៥- របាយការណ៍សវនកម្ម មានសុពលភាពតែក្នុងអំឡុងពេលកិច្ចប្រជុំកំពូល របស់គណៈកម្មាធិការប្រតិបត្តិ (EC) និងអង្គសមាជ។

៦- លក្ខខណ្ឌសវនកម្ម គឺត្រូវបានបញ្ជាក់លម្អិតនៅក្នុងច្បាប់ "ច្បាប់ និងបទបញ្ជាផ្ទៃក្នុង"

៧- គណនេយ្យ នៃអង្គភាពគ្រប់គ្រងរបស់ក្រុមប្រឹក្សាកីឡាក្រសួងមហាផ្ទៃ ត្រូវតែចាត់ចែងដោយផ្អែកតាមគោលការណ៍ច្បាប់របស់រដ្ឋ ដែលបានកំណត់។

## ជំពូកទី៦
## ការកែសម្រួលលក្ខន្តិកៈ ការរំលាយសមាគម

**ប្រការ១៥ : ការកែសម្រួលលក្ខន្តិកៈ**

១- លក្ខន្តិកៈអាចត្រូវបានកែសម្រួល ទៅតាមការស្នើសុំពីសមាជិកភាគច្រើន ដោយមានមូលហេតុ ឬ ស្ថានភាពជាក់ស្តែង និងត្រូវមានការអនុម័តយល់ព្រមដោយសម្លេង ២/៣ ក្នុងកិច្ចប្រជុំរបស់គណៈកម្មាធិការប្រតិបត្តិ។



**ប្រការ១៦ : ការរំលាយសមាគម**

១- អង្គសមាជវិសាមញ្ញ ដែលសម្រេចអំពីការរំលាយសមាគម ត្រូវដោះស្រាយតាមរយៈការប្រជុំ និងដឹកនាំ ដោយផ្អែកលើលក្ខន្តិកៈ។

២- ក្នុងករណីរំលាយសមាគម អង្គសមាជត្រូវតែងតាំងគណៈកម្មការមួយរូប ឬ មួយចំនួនឲ្យទទួលខុសត្រូវទ្រព្យសម្បត្តិ ដែលនៅសេសសល់របស់សមាគម។ អង្គសមាជអាចធ្វើវិភាគទានតម្លៃសុទ្ធនៃទ្រព្យកម្ម ទៅឲ្យគណៈកម្មាធិការកីឡាជាតិផងដែរ។ សមាជសហភាព អាចប្រកាសនូវការចែករំលែកទ្រព្យសម្បត្តិទាំងនេះ ដោយគ្មានលក្ខខណ្ឌសម្រាប់ជាសំណងដល់ថ្លៃឈ្នួលរបស់គេវិញ។

**ប្រការ១៧ : ការទទួលខុសត្រូវរបស់ក្រុមប្រឹក្សា**

១- ក្រុមប្រឹក្សាកីឡាក្រសួងមហាផ្ទៃ (SCIM) បដិសេធនូវការទទួលខុសត្រូវមួយចំនួន។

២- គោលនយោបាយធានារ៉ាប់រងដល់អត្តពលិក មានគោលបំណងសំខាន់ក្នុងការការពារបុគ្គលដែលមានការព្រួយបារម្ភនឹងសុវត្ថិភាពផ្ទាល់ខ្លួន។ ក្នុងន័យនេះគឺមិនជាប់ពាក់ព័ន្ធនឹងកាតព្វកិច្ចមួយចំនួន ឬ ការទទួលខុសត្រូវរបស់សមាគម។

**ប្រការ១៨ : ទីតាំងស្របច្បាប់**

១- រាល់បញ្ហាស្របច្បាប់ទាក់ទងនឹងគោលការណ៍ក្នុងសកម្មភាពចែងដោយលក្ខន្តិកៈ គឺស្ថិតនៅក្រោមសមត្ថកិច្ច របស់អគ្គលេខាធិការ ក្រុមប្រឹក្សាកីឡាក្រសួងមហាផ្ទៃ (SCIM)។

២- បញ្ហាផ្សេងៗដែលនៅសេសសល់ ឬ ជម្លោះដែលមិនអាចដោះស្រាយតាមដំណើរការរដ្ឋបាល គឺស្ថិតនៅក្រោមអំណាចច្បាប់របស់តុលាការ និងសមត្ថកិច្ចរបស់អគ្គលេខាធិការដ្ឋាន។

## ជំពូកទី៧
## ច្បាប់ និងនីតិបញ្ញត្តិ - ការបោះពុម្ពផ្សាយ

**ប្រការ១៩ : ច្បាប់ និងនីតិបញ្ញត្តិ**

ច្បាប់ និងនីតិបញ្ញត្តិ បញ្ជាក់លម្អិតអំពីការគ្រប់គ្រង របស់ក្រុមប្រឹក្សាកីឡាក្រសួងមហាផ្ទៃ (SCIM) ត្រូវរៀបចំដោយគណៈកម្មាធិការប្រតិបត្តិ(EC) និងទទួលបានការអនុម័តដោយអង្គសមាជ។

**ប្រការ២០ : ការបោះពុម្ពផ្សាយ / បទបង្ហាញ**

១- ប្រធានក្រុមប្រឹក្សាកីឡាក្រសួងមហាផ្ទៃ (SCIM) អនុវត្តសេចក្តីប្រកាស និងបោះផ្សាយជូនដំណឹងជាផ្លូវការ ដែលត្រូវបានកំណត់ដោយច្បាប់។

២- រាល់បញ្ហារដ្ឋបាល និងបញ្ហាផ្លូវច្បាប់ ឬ ពាក់ព័ន្ធនឹងបញ្ហាខាងក្នុង ឬ ខាងក្រៅអង្គភាពប្រធាន និងអគ្គលេខាធិការ ត្រូវមានការឯកភាព និងធ្វើបទបង្ហាញរួមគ្នា លើកលែងតែបទបញ្ជាមួយចំនួនដែលមិនមានចែងក្នុងលក្ខន្តិកៈ។

៣- រាល់ឯកសារផ្លូវការត្រូវចុះហត្ថលេខារួមគ្នា ដោយប្រធាន និងអគ្គលេខាធិការ លើកលែងតែឯកសារមួយចំនួន ដែលពាក់ព័ន្ធនឹងការងាររដ្ឋបាលបច្ចេកទេស ត្រូវបានទទួលខុសត្រូវដោយអង្គភាពគ្រប់គ្រងកីឡា។

## ជំពូកទី៨
## ជើងឯកថ្នាក់ជាតិ និងការប្រកួតកីឡាក្នុងកងកម្លាំងនគរបាលជាតិ

**ប្រការ២១ : ការជ្រើសរើសជើងឯក**

១- ក្រុមប្រឹក្សាកីឡាក្រសួងមហាផ្ទៃ (SCIM) រៀបចំការប្រកួតជ្រើសរើសជើងឯកថ្នាក់ជាតិសម្រាប់នគរបាល (PNC) ហ្គេមថ្នាក់ជាតិសម្រាប់សាលានគរបាល (NGPS) និងជំរុញការរៀបចំការប្រកួតកីឡាក្នុងកងកម្លាំងនគរបាលជាតិទូទាំងប្រទេស ក្នុងរយៈពេល ០២ឆ្នាំម្តង។

២- អង្គសមាជមានសិទ្ធិសម្រេច អំពីកម្រិតវិន័យ និងការរៀបចំលក្ខណៈពិសេសក្នុងអំឡុងពេលនៃការប្រកួតជើងឯកម្តងៗ ដោយកំណត់ដាក់បញ្ចូលវិញ្ញាសារជាអាទិភាព សម្រេចដោយគណៈកម្មាធិការរៀបចំការប្រកួត និងគណៈកម្មាធិការបច្ចេកទេសទទួលខុសត្រូវលើការរៀបចំការប្រកួតតាមប្រភេទកីឡានីមួយៗ។

៣- លក្ខខណ្ឌនៃការរៀបចំការប្រកួតនីមួយៗ ត្រូវបាននិយាយលម្អិតនៅក្នុង «បទបញ្ជាផ្ទៃក្នុងនៃការប្រកួត» ។

**ប្រការ២២ : ការប្រកួតកីឡាផ្សេងៗ**

១- ក្នុងន័យនេះគ្របដណ្តប់រាល់ការប្រកួតទាំងអស់ ដែលត្រូវបានរៀបចំតាមកម្រិតជាតិ និងអន្តរជាតិ ហើយនឹងស្របទៅតាមគំនិតផ្តួចផ្តើមរបស់អង្គភាពកីឡាជាតិ (NO) ឬ គណៈកម្មាធិការបច្ចេកទេស របស់ក្រុមប្រឹក្សាកីឡាក្រសួងមហាផ្ទៃ។

២- ផ្លាក "ពានរង្វាន់ថ្នាក់ជាតិសម្រាប់នគរបាល" (PWC) ឬ "ការប្រកួតសម្រាប់នគរបាល" (PNG) អាចត្រូវបានក្លាយជាព្រឹត្តិការណ៍ជាតិ ដែលផ្តោតការយកចិត្តទុកដាក់សំខាន់លើលក្ខខណ្ឌ និងបទបញ្ជាផ្ទៃក្នុង ដែលទទួលស្គាល់ដោយក្រុមប្រឹក្សាកីឡាក្រសួងមហាផ្ទៃ។

**ប្រការ២៣ : អ្នកចូលរួមប្រកួត**

១- ការចូលរួមក្នុងការប្រកួតជ្រើសរើសជើងឯកត្រូវកំណត់ចំពោះអត្តពលិកដូចខាងក្រោម៖

ក- សមស្របតាមតម្រូវការ របស់ក្រុមប្រឹក្សាកីឡាក្រសួងមហាផ្ទៃ

ខ- ជាអង្គភាពកីឡានគរបាលជាតិ ដែលជាសមាជិករបស់ក្រុមប្រឹក្សាកីឡាក្រសួងមហាផ្ទៃ

គ- ជាមន្ត្រីនគរបាល ឬ សិស្សបណ្ឌិត្យសភានគរបាលជាតិកម្ពុជា ដែលមានអាយុ ១៨ឆ្នាំគិតត្រឹមថ្ងៃប្រសូត្រ។

២- ច្បាប់ និងបទបញ្ជាផ្ទៃក្នុង របស់អង្គភាពកីឡានគរបាលជាតិ បានបញ្ជាក់លម្អិតអំពីលក្ខខណ្ឌនៃការចូលរួមការប្រកួត។



**ប្រការ២៤ : រង្វាន់កិត្តិយសនឹងត្រូវផ្តល់ឱ្យអត្តពលិកនគរបាលណាដែលមានទេពកោសល្យ ល្អដាច់គេ / មេដាយកិត្តិយសផ្តល់ដោយសហភាពកីឡានគរបាលជាតិ**

១- អង្គសមាជ នឹងផ្តល់កិត្តិយសជូនអត្តពលិកនគរបាលដែលមានទេពកោសល្យល្អដាច់គេ

២- អត្តពលិកស្រីល្អដាច់គេ អត្តពលិកប្រុសល្អដាច់គេ ឬក្រុមល្អដាច់គេនឹងត្រូវផ្តល់កិត្តិយសនៅអំឡុងពេលប្រកួតជើងឯកពិភពលោកសម្រាប់នគរបាល (WPC) លើសពីនេះទៅទៀតអត្តពលិកស្រី - ប្រុស ដែលទទួលបានលទ្ធផលល្អប្រសើរ នៅអំឡុងពេលប្រកួតលក្ខណៈអន្តរជាតិផ្សេងៗ និងត្រូវបានផ្តល់កិត្តិយស។

៣- ការសម្រេចផ្តល់កិត្តិយស ដល់អត្តពលិក និងត្រូវធ្វើឡើង ដោយគណៈកម្មាធិការប្រតិបត្តិ តាមសំណើរបស់គណៈកម្មាធិការបច្ចេកទេស។ សំណើដែលត្រូវផ្តល់កិត្តិយ សម្រាប់បុគ្គលម្នាក់ៗ អាចត្រូវបានផ្ញើទៅតាមរយៈសមាជិកភាព និងសមាជិក នៃគណៈកម្មាធិការបច្ចេកទេស ។

៤- រង្វាន់កិត្តិយសរបស់អង្គភាពកីឡានគរបាលជាតិ (NPSUC) និងត្រូវដាក់បង្ហាញជូនគណៈកម្មាធិការប្រតិបត្តិ និងសម្រេចផ្តល់រង្វាន់មេដាយ ដោយផ្អែកលើពេលវេលា ដែលមានចែងនៅក្នុង "ច្បាប់ និងបទបញ្ជាផ្ទៃក្នុង" ។

**ប្រការ២៥ : សិទ្ធិការពារខ្លួន**

១- សមាជិកភាពនៃក្រុមប្រឹក្សាកីឡាក្រសួងមហាផ្ទៃ (SCIM) មានសិទ្ធិដើម្បីប្តឹងតវ៉ាទៅគណៈកម្មាធិការប្រតិបត្តិ ឬ អង្គសមាជអំពីទណ្ឌកម្ម ដែលប្រើប្រាស់លើសមាជិកណាម្នាក់របស់ខ្លួន ។

**ប្រការ២៦ : ការចូលជាធរមាននៃលក្ខន្តិកៈ**

១- រាល់បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយពីការកំណត់ក្នុងលក្ខន្តិកៈនេះ ត្រូវទុកជានិរាករណ៍

២- លក្ខន្តិកៈនេះត្រូវបានចូលជាធរមាន និងមានសុពលភាពច្បាប់អនុវត្តន៍ជាអចិន្ត្រៃយ៍ ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

ថ្ងៃ សុក្រ ៦រោច ខែ មិគសិរ ឆ្នាំ កុរ ឯកស័ក ព.ស ២៥៦៣

រាជធានីភ្នំពេញ, ថ្ងៃទី ២៨ ខែ ធ្នូ ឆ្នាំ ២០១៩

បានឃើញ និងឯកភាព

**ក្រុមប្រឹក្សាកីឡាក្រសួងមហាផ្ទៃ**

**ប្រធាន**

**សម្តេចក្រឡាហោម ស ខេង**

**អគ្គលេខាធិការ**

ឧត្តមសេនីយ៍ឯក.**ជា-ប៊ុនហេង**